# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHRC)
# បណ្តឹងលេខ១៤២១/២០០៥

**១.ពាក្យគន្លឹះ៖** ទោសប្រហារជីវិត, សិទ្ធិរបស់ជនជាប់ចោទទទួលបានសវនាការដោយគ្មានបង្អង់យូរ

**២. នីតិវិធី៖** អ្នកប្តឹង (ជនជាប់ចោទ) Mariano ជនជាតិហ្វីលីពីន ត្រូវបានឃាត់ខ្លួនក្នុងឆ្នាំ ១៩៩៦ ជាប់ទោសពីបទមនុស្សឃាត នឹងទទួលទោសប្រហារជីវិត (១៩៩៩) ដែលកំពុងរង់ចាំការប្រហារជីវិត (death row phenomena)។ មុនយុត្តិសាស្ត្រ *Mateo* របស់តុលាការកំពូល ជនជាប់ចោទ ដែលមានទោសប្រហារជីវិត ត្រូវបានបញ្ជូនទៅតុលាការកំពូលឲ្យពិនិត្យដោយស្វ័យប្រវត្តិ (automatic review) ដោយមិនចាំបាច់មានបណ្តឹងរបស់ជនជាប់ចោទទេ។ ក្រោយពីយុត្តិសាស្ត្រនេះ លែងមានការត្រួតពិនិត្យជាស្វ័យប្រវត្តិហើយ ដោយត្រូវប្តឹងទៅសាលាឧទ្ធរណ៍សិន និងប្តឹងមកតុលាការកំពូល។ ដូចនេះ សំណុំរឿងក្នុងដៃរបស់តុលាការកំពូល មិនទាន់ត្រូវបានដោះស្រាយ ត្រូវផ្ទេរមកសាលាឧទ្ធរណ៍វិញ។

សំណុំរឿងរបស់ជនជាប់ចោទ ស្ថិតនៅក្នុងដៃតុលាការកំពូលចំនួន៥ឆ្នាំហើយ ហើយគាត់បានស្នើសុំកុំឲ្យតុលាការកំពូលផ្ទេរមកសាលាឧទ្ធរណ៍ ដោយបារម្ភពីការយឺតយ៉ាវជាបន្ថែម។ តុលាការកំពូល បានសម្រេចបដិសេធ និងបញ្ជូនសំណុំរឿងមកសាលាឧទ្ធរណ៍ក្នុងឆ្នាំ ២០០៥។ ក្រោយមក ដោយសារបញ្ហាផ្ទៃក្នុង សមាជិកថ្មីនៃសាលាឧទ្ធរណ៍ ត្រូវបានចាត់តាំងឲ្យពិនិត្យសំណុំរឿងនេះ។

ជនជាប់ចោទ អះអាងថា ដោយសារយឺតយូររយៈពេលជាង៥ឆ្នាំ ទើបបញ្ជូនមកសាលាឧទ្ធរណ៍ ដែលថ្មីលើសំណុំរឿង នឹងនាំឲ្យមានភាពយឺតយ៉ាវ និងប៉ះពាល់ដល់ការប្តឹង និងដោះស្រាយបណ្តឹឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព។ នេះនាំឲ្យមានការបំពានមាត្រា១៤ (៣.គ) នៃកតិកាសញ្ញា។ រដ្ឋភាគី បានឆ្លើយថា ការយឺតយ៉ាវនេះ លុះត្រាតែធ្ងន់ធ្ងរ ទើបជាការបំពាន។ រឿងក្តីនេះ សេចក្តីសម្រេច អាចមានក្នុងឆ្នាំ២០០៤ហើយ នៅខណៈដែលសារណារបស់គ្រប់ភាគី ត្រូវបានដាក់ជូន (នៅតុលាការកំពូល) ហើយមិនដល់១ឆ្នាំផង ក្នុងឆ្នាំ២០០៥ ក្រោយទទួលសារណា តុលាការកំពូលបានសំណុំរឿងបញ្ជូនមកសាលាឧទ្ធរណ៍។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច

**ក.** តាមអង្គហេតុ គណៈកម្មាធិការ រកឃើញថា ជនជាប់ចោទ ត្រូវបានឃុំខ្លួនតាំងពីឆ្នាំ ១៩៩៦ រហូតដល់ឆ្នាំ ១៩៩៩ ទើបរកឃើញមានទោស ហើយសំណុំរឿងនេះស្ថិតនៅក្នុងដៃតុលាការកំពូល៥ឆ្នាំ ដោយគ្មានសម្រេច រហូតដល់ការផ្ទេរមកសាលាឧទ្ធរណ៍ឆ្នាំ ២០០៥ ហើយមកដល់ពេលនេះ មានរយៈពេលបន្ថែម ៣ឆ្នាំទៀតនៅមុខ សាលាឧទ្ធរណ៍។ នេះជាការពន្យាមួយ មិនសមហេតុផល (ប្រហែល៨ឆ្នាំ) ដែលជាការបំពានមាត្រា ១៤(៣.គ)។

ខ. បណ្តឹងពាក់ព័ន្ធនឹងការបំពានមាត្រា៦ លែងមានសុពលភាពហើយ (moot) ដោយសារ នៅឆ្នាំ ២០០៦ សភានៃប្រទេសហ្វីលីពីន បានលុបចោលទោសប្រហារជីវិត។

## ៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)

*សិទ្ធិរបស់ជនជាប់ចោទទទួលបានសវនាការដោយគ្មានបង្អង់យូរ មិនគ្រាន់តែទាក់ទងដល់ពេលវេលាចន្លោះពីការចោទប្រកាន់ជាផ្លូវការ និងពេលដែលសវនាការបានចាប់ផ្តើមទេ តែទាក់ទងផងដែរដល់ពេលវេលា រហូតដល់សាលដីកាស្ថាពរ លើបណ្តឹងឧទ្ធរណ៍។ ដំណាក់កាលទាំងអស់នៅឯសាលាដំបូង ឬឧទ្ធរណ៍ ត្រូវបានបញ្ចប់ទាំងស្រុង ដោយគ្មានបង្អែបង្អង់មិនសមស្រប* (កថាខ័ណ្ឌទី ៨.៣)។

*គណៈកម្មាធិការរំលឹកថា សិទ្ធិរបស់ជនជាប់ចោទទទួលបានសវនាការដោយគ្មានបង្អង់យូរ មិនគ្រាន់តែក្នុងគោលបំណងជៀសនូវការទុកមនុស្សយូរក្នុងស្ថានភាពមិនច្បាស់លាស់អំពីជោគវាសនាទេ ហើយប្រសិនបើមានការឃុំខ្លួនក្នុងអំឡុងពេលសវនាការ គឺដើម្បីធានាថា ការដកហូតនូវសិទ្ធិសេរីភាព មិនយូរពេលជាងភាពចាំបាច់ក្នុងស្ថានភាពនៃករណីជាក់លាក់ ក៏ប៉ុន្តែថែមទាំង ក្នុងគោលបំណងបម្រើប្រយោជន៍យុត្តិធម៌* (កថាខ័ណ្ឌទី៨.៤)។

*រដ្ឋភាគី មានកាតព្វកិច្ចក្នុងការដឹកនាំប្រព័ន្ធរដ្ឋបាលយុត្តិធម៌ ក្នុងលក្ខណៈដើម្បីធានានូវការចាត់ចែងសំណុំរឿងឲ្យបានឆាប់ និងមានប្រសិទ្ធភាព* (កថាខ័ណ្ឌទី៨.៥)។

ទស្សនៈទាំងស្រុងសូមមើល៖ CCPR/C/92/D/1466/2006, Communication No. 1466 (Mariano v. the Philippines)